**សេចក្តីប្រកាសព័ត៌មាន**

ភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១

# ក្រុមហ៊ុនអ៊ិនធើ ឡូជីស្ទីក (ខេមបូឌា) បានទិញភាគហ៊ុនចំនួន ៤៥,០៩ ភាគរយ នៃភាគហ៊ុនសរុប របស់ ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី

**ក្រុមហ៊ុនអ៊ិនធើ ឡូជីស្ទីក (ខេមបូឌា)** ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ **ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប** បានទិញភាគហ៊ុនចំនួន **៤៥,០៩%** នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) និងបានក្លាយជា ភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់។

**ក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី** គឺជាក្រុមហ៊ុនដែលបានជួយរៀបចំ និងជាឈ្មួញជើងសារនៃប្រតិបត្តិការទិញ-លក់ភាគហ៊ុនរបស់ក្រុមហ៊ុន **ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី** ("**ភីភីអេសភី**") ដែលជាតំបន់សេដ្ឋកិច្ចពិសេសឈានមុខគេនៅក្នុងប្រទេសកម្ពុជា។

**ភីភីអេសភី** គឺជាក្រុមហ៊ុនគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសឈាមមុខគេនៅកម្ពុជា ដែលបានផ្តល់ការងារដល់ប្រជាជនកម្ពុជា និងបុគ្គលិកបរទេសប្រមាណជាង ៣២.០០០នាក់ (គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២១) និងបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ក្រុមហ៊ុនដែលនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះ ដូចជាការលើកលែងពន្ធគយ ពន្ធលើប្រាក់ចំណូល និងពន្ធផ្សេងៗទៀត ជួយកាត់បន្ថយការចំណាយលើហេដ្ឋារចនាសម្ព័ន្ធ ទឹកភ្លើង វត្ថុធាតុដើម និងធនធានផ្សេងៗដែលបង្កើនការប្រកួតប្រជែងក្នុងការនាំចេញ និងផ្តល់អត្ថប្រយោជន៍ដល់ពាណិជ្ជកម្ម អន្តរជាតិផងដែរ។

នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦ **ភីភីអេសភី** បានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ធ្វើជាក្រុមហ៊ុនអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ដែលមានអាជីវកម្មចម្បង គឺការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ និងជួល។ លើសពីនេះទៅទៀត ក្រុមហ៊ុនក៏មានផ្តល់សេវាកម្មផ្សេងៗទៅដល់ក្រុមហ៊ុនដែលនៅក្នុងបរិវេណតំបន់សេដ្ឋកិច្ចពិសេស **ភីភីអេសភី** ផងដែរ ដែលរួមមានដូចជា ការផ្គត់ផ្គង់ និងចែកចាយទឹកស្អាត ការថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មផ្តល់ប្រឹក្សាយោបល់ ជំនួយកិច្ចការរដ្ឋបាល ប្រព្រឹត្តិកម្មទឹកកខ្វក់ និងសេវាកម្មដទៃទៀត។ ភីភីអេសភី បានក្លាយជាក្រុមហ៊ុនចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange) នៅក្នុងឆ្នាំ២០១៦។

**អ្នកឧកញ៉ា គិត ម៉េង ប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប និងជាប្រធានក្រុមហ៊ុន អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា)** បានមានប្រសាសន៍ថា៖ "ការវិនិយោគទិញភាគហ៊ុនមួយនេះ គឺជាការបោះជំហានមួយដ៏មានសារៈសំខាន់សម្រាប់ការអភិវឌ្ឍរបស់ **ក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុប។ ភីភីអេសអី** គឺជាក្រុមហ៊ុនគ្រប់គ្រងតំបន់សេដ្ឋកិច្ចមួយក្នុងចំណោមក្រុមហ៊ុនគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសដំបូងគេ និងធំជាងគេនៅក្នុងប្រទេសកម្ពុជា ដែលបានរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជា តាមរយៈការពាំនាំយកក្រុមហ៊ុនផលិត និងសេវាកម្មចំនួនជាង ៩៥ ក្រុមហ៊ុន មកពី ១២ ប្រទេស និងផ្ដល់ការងារដល់បុគ្គលិកជាង ៣២.០០០នាក់។ តំបន់សេដ្ឋកិច្ចពិសេសបានផ្ដល់សេវាកម្មដល់ក្រុមហ៊ុនដែលមកពីប្រទេស ជប៉ុន ប្រទេសចិន សិង្ហបុរី សហរដ្ឋអាមេរិក ម៉ាឡេស៊ី ហូឡង់ និងអូស្ត្រាលី ក្នុងវិស័យផ្សេងៗគ្នា ដូចជា គ្រឿងបន្លាស់រថយន្ត សម្លៀកបំពាក់ អាហារ និងភេសជ្ជៈ ផលិតផលប្លាស្ទិក ផលិតផលអេឡិចត្រូនិក និងគ្រឿងអលង្ការ។ នៅក្នុងការវិនិយោគនេះទៀតសោត យើងនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងអ្នកគ្រប់គ្រងរបស់ **ភីភីអេសអី** ដើម្បីនាំមកនូវប្រព័ន្ធបច្ចេកវិទ្យាថ្មីៗ ការគ្រប់គ្រង និងយុទ្ធសាស្ត្រអាជីវកម្ម និងអ្នកវិនិយោគបន្ថែមទៀត ដើម្បីបន្តអភិវឌ្ឍក្រុមហ៊ុន និងរួមចំណែកក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិផងដែរ"៕

ប្រតិបត្តិការទិញ-លក់ភាគហ៊ុននេះ បានទទួលការអនុញ្ញាតយល់ព្រមពីនិយ័តករមូលបត្រកម្ពុជានៅថ្ងៃទី17 ខែធ្នូ ឆ្នាំ២០២១ យោងទៅតាមលិខិតលេខ 2050/21 ន.ម.ក៕

**ទំនាក់ទំនង**

**លោក សេង ចាន់ធឿន** | **លេខទូរស័ព្ទ**: +855 77 333 629
**នាយកប្រតិបត្តិ**
**អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូរីធី**